ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ : 1705 PEAC.អក

## សេចក្តីជូនដំណឹង
## ស្តីពី
## ការសាងសង់បន្ទប់ភ្លើងទំហំ 4.5m x 5m x 4.65m ចំនួនមួយខ្នងលើ
## ទីតាំងប៉ុស្តិ៍ចល័ត PTT 032 ,ភូមិដីហុយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
## ជូនអង្គភាពបណ្តាញនៃនាយកដ្ឋានអាជីវកម្មចែកចាយ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា : អគ្គិសនីកម្ពុជានឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការការសាងសង់បន្ទប់ភ្លើងទំហំ 4.5m x 5m x 4.65m ចំនួនមួយខ្នងលើទីតាំងប៉ុស្តិ៍ចល័ត PTT 032 ,ភូមិដីហុយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជូនអង្គភាពបណ្តាញនៃ នាយកដ្ឋានអាជីវកម្មចែកចាយ ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ក្រុមហ៊ុន / សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ ។ ឯកសារពិគ្រោះថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មដែលមានអាស័យដ្ឋាន :ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញចាប់ពី ថ្ងៃទី ០៧-១១-២០១៦ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ : 023 6766 007 និង Website WWW.edc.com.kh ) ។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹម ថ្ងៃទី ២៩-១១-២០១៦ វេលាម៉ោង ១១:00 នាទី ។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាសយដ្ឋានខាងលើ វេលាម៉ោង ១៥ : 00 នាទី ថ្ងៃទី ២៩-១១-២០១៦ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/ សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និង សាកសួរពតិមានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ 11 ឆ្នាំ ២០១៦

ជ. ប្រធានគណៈកម្មាធិការលទ្ធកម្ម

ង៉ែត_សុខន

ចម្លងជូន :
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ